**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៣ ០២១ ២៩៤ ប្រ.ក

# ប្រកាស
## ស្តីពី
## លក្ខណៈសម្គាល់នៃធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ៣០០០០ រៀល

អនុលោមទៅតាមអនុក្រឹត្យលេខ ២០០អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ស្តីពីការចេញផ្សាយធនប័ត្រ អនុស្សាវរីយ៍ ប្រភេទ ៣០០០០ រៀល ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាស ផ្សាយជាសាធារណៈនូវលក្ខណៈសម្គាល់នៃធនប័ត្រអនុស្សាវរីយ៍នេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ : បណ្តោយ ១៧០ មម ទទឹង ៧៥ មម
- ពណ៌ចម្បងគឺពណ៌បៃតង ពណ៌ត្នោត និងពណ៌ស្វាយ

**ខ- ផ្ទៃខាងមុខ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍មើលចំពីមុខនៃ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** នាឱកាសកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលផ្ទៃខាងក្រោយត្រូវបានតែងលម្អដោយក្បាច់ចម្លាក់ជាប្រពៃណី ក្នុងព្រះបរមរាជវាំងភ្នំពេញ ព្រមជាមួយអក្សរ "បីម៉ឺនរៀល" នៅខាងក្រោម ។ ខាងឆ្វេងមានលេខ "៣០០០០" នៅពីលើ ព្រមទាំងហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡាខិតមកក្រោមមានរូបចម្លាក់ នាគក្បាល៥ នៅវិមានឯករាជ្យរាជធានីភ្នំពេញ និងមានបង្អួចថ្លារាងចតុកោណស្មើបញ្ឈរកែង ដែលមាន សមាសធាតុជាប៉ូលីមែរនៅអមក្បែរនោះ ។

- **ផ្នែកខាងស្តាំ** ខាងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ខិតមកក្រោមលេខមាលាបោះពុម្ព ដោយទឹកខ្មៅពីរពណ៌ គឺតួមាលានិងលេខ "30" បោះពុម្ពដោយទឹកខ្មៅពណ៌ក្រហមនិងលេខ ៦ ខ្ទង់ ទៀតបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ នៅពីក្រោមនោះមានលេខ "៣០០០០" និង "30000" និងមាន អក្សរ "អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់" នៅគែមខាងក្រោម ។ នៅគែមខាងស្តាំនៃ ក្រដាសប្រាក់ មានរូបភាពអង្គរដៅចំណាំបោះពុម្ពតាមបន្ទាត់បញ្ឈរដែលឆ្លុះឃើញមានលេខ "30000" ។

- **ផ្នែកខាងឆ្វេង** ខាងលើមានរូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា និងមានលេខ "30000" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរនៅពីក្រោមនោះ ព្រមជាមួយបន្ទះហូឡូក្រាមទំហំ ១០មម កាត់ទទឹង ផ្ទៃក្រដាសប្រាក់ពីលើដល់ក្រោម ។ នៅជ្រុងខាងក្រោមមានគំនូសបន្ទាត់សម្រាប់ផ្ទៀងផ្ទាត់ និង និមិត្តសញ្ញាពិសេសសម្គាល់ប្រភេទប្រាក់សម្រាប់ជនពិការភ្នែក ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**គ- ផ្ទៃខាងខ្នង ៖**

- **ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវ **ព្រះឆាយាល័ក្ខណ៍ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ** "**ព្រះបរមរតនកោដ្ឋ**" និង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាឱកាសនៃការយាងនិវត្តន៍មកកាន់មាតុភូមិវិញរបស់ ព្រះករុណាព្រះបរមរតនកោដ្ឋ នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩១ និងមានអក្សរ "បីម៉ឺនរៀល" នៅពីក្រោម និងអក្សរ "*Le 30 Anniversaire des Accords de Paris sur le Cambodge (1991 - 2021)* នៅគែមក្រដាសប្រាក់ ។

- **ផ្នែកខាងស្តាំ** ត្រូវបានរំលេចឡើង នូវរូបវិមានឯករាជ្យនៅរាជធានីភ្នំពេញ ប៉មអៃហ្វែល នៅទីក្រុងប៉ារីស រូបសន្និសីទនៃការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងមានបង្អួចថ្លារាងចតុកោណស្មើបញ្ឈរកែងមានសមាសភាពជាប៉ូលីមើរ នៅផ្នែកខាងក្រោម ព្រមជាមួយខ្សែសុវត្ថិភាពទំហំ ៤មម នៅផ្នែកខាងឆ្វេង ។ នៅជ្រុងលើខាងស្តាំមានលេខ "30000" ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បញ្ឈរ ។

- **ផ្នែកខាងឆ្វេង** ខាងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ខាងក្រោមមានចារឹកអក្សរ "អបអរសាទរខួប ៣០ឆ្នាំ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស (១៩៩១ - ២០២១) ខិតមកក្រោមមានអក្សរ BANQUE NATIONALE DU CAMBODGE ព្រមទាំងលេខ "2021" និងលេខ "៣០០០០" នៅពីក្រោមនោះ ។ នៅគែមខាងឆ្វេងនៃក្រដាសប្រាក់មានរូបភាពអង្គដៅចំណាំ បោះពុម្ពតាមបន្ទាត់បញ្ឈរដែលឆ្លុះឃើញលេខ "30000" ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រអនុស្សាវរីយ៍ប្រភេទ ៣០០០០ រៀល ត្រូវបានដាក់ឲ្យចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀត ដែលត្រូវបានចេញផ្សាយកន្លងមក ។ សាធារណជនគ្រប់រូប ត្រូវពិនិត្យ-សម្គាល់ធនប័ត្រថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីចៀសវាងការភាន់ច្រឡំ ។

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១

**ទេសាភិបាល**

ជា-ចាន់តូ